គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750
E-mail: comfrel@online.com.kh or comfrel@forum.org.kh Site: http://www.comfrel.org
ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធន សារាយ
Mr. THUN SARAY
ជាតំណាងទី១ និង
ប្រធាន ADHOC

លោកស្រី អ៊ុង ចាន់ធុល
Ms. OUNG Chanthol
ជាតំណាងទី២ និង
នាយិកា CWCC

លោក យឹម ពៅ
Mr. YIM Po អគ្គលេខាធិការ
និងនាយក CCPCR

លោក សុខ សំអឿន
Mr. SOK Sam Oeun
នាយក CDP

លោកស្រី ទិវ សារ៉ាយ៉េត
Ms. TIV Sarayet
សហនាយិកា WMC

លោក យ៉ង់ គិមអេង
Mr. YONG Kim Eng
ប្រធាន KYA

លោក អ៊ុក វណ្ណដេត
Mr. OUK Vandeth
នាយក LAC

លោក ស៊ីល វិនេត្រ
Mr. SIL Vinet នាយក SEDOC

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សេន សែត
Mr. SEN Set

លោក មុំ សារិន
Mr. MOM Sarin
នាយក KKKHRA

លោក ទូច ទុម
Mr. Touch Tum
នាយក VIGILANCE

ស.ប្រ.ក/លេខ ០៦/០៧ គ.យ.ស.ប/អ.ក

# សេចក្តីថ្លែងការណ៍
# ស្តីពី
# ការវាយតម្លៃបរិយាកាសមុនយុទ្ធនាការឃោសនាបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧

*ភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៧*

**គណៈកម្មាធិការខុមហ្វ្រែល** វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលមានសមាសភាពចេញមកពីគណបក្សនយោបាយទាំងបី (មានអាសនៈក្នុងសភា) បានអនុវត្តការងារមានតម្លាភាពជាងមុន ដូចជាការចេញសេចក្តីណែនាំអំពីអព្យាក្រឹតភាពអាជ្ញាធរ-ភូមិ ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ការរៀបចំឱ្យមានកម្មវិធីផ្សព្វផ្សាយកម្មវិធីគោលនយោបាយរួមរបស់គណបក្ស និងគោលការណ៍ណែនាំស្តីពីក៏រិតនៃកំហុស ទិន្នន័យរវាងបញ្ជីឈ្មោះ និងឯកសារបញ្ជាក់អត្តសញ្ញាណ ដែលអាចប្រើប្រាស់ក្នុងថ្ងៃបោះឆ្នោតបាន។ ជាមួយគ្នានេះដែរ ក៏សូមធ្វើការកោតសរសើរចំពោះក្រសួងព័ត៌មាន និង គជប ដោយមានការឧបត្ថម្ភគាំទ្រពីម្ចាស់ជំនួយតាមរយៈ UNDP ដែលបានធ្វើឱ្យកើតមានឡើងវិញកម្មវិធីព័ត៌មានសមធម៌ សំរាប់គណបក្សទាំងអស់។

គណបក្សនយោបាយភាគច្រើន មានភាពសកម្មក្នុងការចូលរួមប្រកួតប្រជែងការបោះឆ្នោត។ គណបក្សនយោបាយចូលរួមប្រកួតក្នុងការបោះឆ្នោត មានចរិតចាស់ទុំច្រើនក្នុងការដោះស្រាយបញ្ហានានា ហើយបានដាក់បេក្ខជនជាស្ត្រី ដែលមានចំនួនកើនឡើងបើប្រៀបធៀបជាមួយការបោះឆ្នោតឆ្នាំ ២០០២។

ទោះបីយ៉ាងនេះក្តី **គណៈកម្មាធិការខុមហ្វ្រែល** មានការព្រួយបារម្ភលើបរិយាកាសអសន្តិសុខ និងកើនឡើងករណីឃាតកម្មប៉ះពាល់ដល់សមាជិក និងបេក្ខជននៃគណបក្សនយោបាយនៅក្រោយពេលចុះបញ្ជីបេក្ខជនគណបក្សនយោបាយ។ លោក ធន សារាយ តំណាងទី ១ ខុមហ្វ្រែល បានលើកឡើងថាៈ *"ករណីឃាតកម្ម និងហិង្សាលើសកម្មជននយោបាយ បើរាប់ជាចំនួនករណីមានការថយចុះមួយចំនួន បើប្រៀបធៀបជាមួយការបោះឆ្នោតមុនៗ ប៉ុន្តែគេនៅពុំទាន់អាចវាស់បាននូវផលប៉ះពាល់នៃករណីឃាតកម្ម និងហិង្សាទាំងនេះបាននៅឡើយទេ។"*

មានការថប់បារម្ភផងដែរថា ដំណើរការបោះឆ្នោត និងទីលានប្រកួតប្រជែងយុទ្ធនាការឃោសនាបោះឆ្នោតត្រឹម-ត្រូវ និងយុត្តិធម៌ បាននិងកំពុងទទួលរងការគំរាមកំហែង និងជួបឧបសគ្គ។ ការប្តឹងផ្តល់ និងការកាត់ទោសដាក់ពន្ធនាគារចំពោះសម្តេចក្រុមព្រះ ដោយទទួលរងឥទ្ធិពលរបស់នាយករដ្ឋមន្ត្រីបានក្លាយជា "**បញ្ហានយោបាយ**" ដែលនឹងរារាំងការចូលរួមរបស់ព្រះប្រធានគណបក្ស នរោត្តម រណឫទ្ធិ ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតនាពេលខាងមុខនេះ។

ម្យ៉ាងទៀតតាមទូរទស្សន៍រដ្ឋ និងឯកជនស្ទើរទាំងអស់បានធ្វើព័ត៌មាន និងផ្សព្វផ្សាយលំអៀងយ៉ាងខ្លាំងទៅគណបក្សប្រជាជនកម្ពុជា។ គណបក្សប្រជាជនកម្ពុជាបានយកប្រៀបជាខ្លាំងក្នុងការប្រើប្រាស់ធនធាន និងសម្ភារៈរបស់រដ្ឋដើម្បីធ្វើសកម្មភាពឃោសនា និងចែកអំណោយ (ជាសំភារៈ និងថវិកាជាដើម)។

ការសង្កេតរកឃើញថា បញ្ជីឈ្មោះបោះឆ្នោតផ្លូវការមិនទាន់មានគុណភាព បានបង្កជាការព្រួយបារម្ភយ៉ាងខ្លាំងពីសំណាក់គណបក្សនយោបាយមួយចំនួន និងអ្នកបោះឆ្នោតជាច្រើន ដែលបានរអ៊ូរទាំអំពីបញ្ហាខុសទិន្នន័យនានាវវាងបញ្ជី-ឈ្មោះ និងឯកសារបញ្ជាក់អត្តសញ្ញាណ។ ដំណើរការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតលើកទី ២ នេះ នៅតែជាការព្រួយបារម្ភដដែល ដោយសារតែចំនួនប័ណ្ណដែលបានចែកនៅតែមិនទាន់បានដល់ដៃ អ្នកបោះឆ្នោតប្រហែលចំនួន ១ លាន ៤សែននាក់ មានន័យថា នៅមានអ្នកបោះឆ្នោតជាច្រើនមិនទាន់បានទទួល ព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតរបស់ខ្លួននៅឡើយ។ ការសង្កេតឃើញនៅតែមានភាពមិនប្រក្រតីអំពីការរើសអើងគណបក្សនយោបាយ ប្រសិទ្ធភាពនៃការចែកមានការយឺត ការមិនគោរពតាមសេចក្តីណែនាំ នៅតែបន្តកើតមានឡើង។

ដើម្បីប្រមូលបានព័ត៌មាន និងទិន្នន័យទាំងនេះ **ខុមហ្វ្រែល** បានដាក់ពង្រាយ **អ្នកសង្កេតការណ៍រយៈពេលវែង**ដែលគ្របដណ្តប់ឃុំ/សង្កាត់ ៦០០ នៃខេត្ត/ក្រុងទាំង២៤។ **ខុមហ្វ្រែល** ក៏មាន**ក្រុមអ្នកអង្កេតការណ៍លើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន** ដែលបាននិងកំពុងធ្វើការអង្កេតលើប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដូចជា ទូរទស្សន៍ជាតិកម្ពុជា បណ្តាញទូរទស្សន៍កម្ពុជា (CTN) វិទ្យុជាតិកម្ពុជា ក៏រិត FM 96 MHz, AM 918 KHz វិទ្យុអាស៊ីសេរី វិទ្យុសំលេងសហរដ្ឋអាមេរិក និងវិទ្យុបារាំងអន្តរជាតិ។ **ខុមហ្វ្រែល** បានរៀបចំជាគណៈប្រតិភូនៃអង្គការសង្គមស៊ីវិល ដើម្បីជួបជាមួយថ្នាក់ដឹកនាំគណបក្សនយោបាយដែលចូលរួមប្រកួតក្នុងការបោះឆ្នោត ក្នុងគោលបំណងសិក្សាស្វែងយល់ ផ្លាស់ប្តូរព័ត៌មាន និងពិភាក្សាអំពីបញ្ហាបោះឆ្នោតដែលគណបក្សនយោបាយជួបប្រទះ។

**<u>អនុសាសន៍:</u>**

*១- ទូលព្រះបង្គំយើងខ្ញុំ សូមទូលស្នើ ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះ-រាជាណាចក្រកម្ពុជា ព្រះមេត្តាចេញជាព្រះរាជសារទៅកាន់អ្នកបោះឆ្នោត និងគណបក្សនយោបាយ កុំឱ្យប្រព្រឹត្តអំពើហិង្សា ក្នុងដំណើរការឃោសនាបោះឆ្នោត និងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោតនាពេលខាងមុខ ដើម្បីជាទឹកក់ក្តៅដល់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។*

*២- គជប និងក្រសួងមហាផ្ទៃ ត្រូវជំរុញការអនុវត្តន៍ឱ្យបានតឹងរឹងក្នុងការចាត់វិធានការរំភេមុខរកជនដៃដល់ មកផ្តន្ទាទោសតាមច្បាប់ជាធរមាន។*

៣- គជប ត្រូវធានាថា គណបក្សនយោបាយដែលចូលរួមប្រកួតក្នុងការបោះឆ្នោតទាំងអស់ មានសិទ្ធិដូចគ្នា និងដោយសេរី(គ្មានការរារាំង) ក្នុងការធ្វើសកម្មភាពនានាទាំងមុន និងនៅក្នុងដំណាក់កាលឃោសនាបោះឆ្នោតផ្លូវការ ។

៤- ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវតែបានជំរុញឱ្យគោរពនូវក្រមសីលធម៌ គោលការណ៍សំរាប់ប្រព័ន្ធផ្សព្វផ្សាយ និងគោលការណ៍សមធម៌ ដែលបានចែងដោយ គជប និងក្រសួងព័ត៌មាន ។

៥- គជប ត្រូវជំរុញក្រុមពាក់ព័ន្ធការបោះឆ្នោតដូចជា គណបក្សនយោបាយ អង្គការសង្គមស៊ីវិល គឃ សប ឱ្យបន្តចែកប័ណ្ណព័ត៌មានទៅអ្នកបោះឆ្នោតដោយស្ម័គ្រចិត្ត ។

សំរាប់ព័ត៌មានលំអិតសូមទាក់ទង:

- លោក **ធន សារាយ** តំណាងទី១ ខុមហ្វ្រែល ០១៦ ៨៨ ០៥ ០៩
- លោក **យង់ គិមអេង** សមាជិកគណៈកម្មាធិការនាយក ខុមហ្វ្រែល ០១៦ ៨២ ៨២ ១១
- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧

**ខាងក្រោមនេះ គឺជារបាយការណ៍លំអិត :**

១- <u>បញ្ហាសន្តិសុខៈ ឃាតកម្ម គំរាមកំហែង និងបំភិតបំភ័យ</u>

ជាទូទៅ ការសង្កេតរកឃើញថា បរិយាកាសក្រោយពេលចុះបញ្ជីបេក្ខជនគណបក្សនយោបាយ មាន**ករណីអសន្តិសុខកើនឡើង**នៅតាមបណ្តាខេត្ត/ក្រុងមួយចំនួន បើប្រៀបធៀបនឹងកំឡុងពេលធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត។

**ការកើនឡើងនូវ ករណីឃាតកម្ម និងការគំរាមកំហែង** ទៅលើសមាជិកគ្រួសារ សកម្មជន បេក្ខជន គណបក្សនយោបាយ និងសកម្មជនផ្សេងៗទៀតក្នុងអំឡុងពេលនេះ។ ជាក់ស្តែង ក្នុងអំឡុងចាប់តាំងពីខែ មករា រហូតមកដល់ខែមីនានេះ យ៉ាងហោចណាស់ មានករណីឃាតកម្មទៅលើសមាជិកគ្រួសារ និងបេក្ខជន **គណបក្សសមរង្ស៊ី ចំនួន ២ ករណី** កើតឡើងនៅខេត្តព្រះវិហារ និងខេត្តបាត់ដំបង ករណីឆេះផ្ទះបេក្ខជនគណបក្សសមរង្ស៊ីនៅខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ឆ្នាំង **ករណីផ្ទុះគ្រាប់បែកស្លាប់កូនស្រីបេក្ខជនលំដាប់ទី១ គណបក្សនរោត្តមរណឫទ្ធិ**នៅខេត្តពោធិ៍សាត់ ករណីឆេះផ្ទះបេក្ខជនគណបក្ស នរោត្តម រណឫទ្ធិនៅក្រុងប៉ៃលិន ករណីឃាតកម្មទៅលើប្តីបេក្ខនារី**គណបក្សប្រជាជនកម្ពុជា** នៅខេត្តក្រចេះ ករណីឃាតកម្មទៅសមាជិកគណបក្សប្រជាជនកម្ពុជានៅខេត្តកំពង់ធំ (**សរុប ២ ករណី**)។ ភាគច្រើននៃករណីទាំងនេះ ត្រូវបានអាជ្ញាធរមូលដ្ឋានធ្វើការអះអាងជំហានដំបូងថា ជាអំពើប្លន់ ឬឧប្បត្តិហេតុផ្សេងៗ មិនពាក់ព័ន្ធនឹងបញ្ហានយោបាយ។

នៅក្នុងអំឡុងខែកុម្ភៈនេះ **មានការកើនឡើងនូវបញ្ហាអសន្តិសុខ**នៅតាមខេត្ត/ក្រុងមួយចំនួន រាប់ចាប់តាំងពីចោរលួច ប្លន់ រហូតដល់ករណីឃាតកម្មដែលកើតមានឡើងនៅខេត្តកំពង់ចាម បាត់ដំបង ក្រុងព្រះសីហនុ និងរាជធានីភ្នំពេញ។ ជាក់ស្តែងនៅក្រុងភ្នំពេញ និងខេត្តកណ្តាល មានករណីបាញ់ប្រហារទៅលើសិល្បការិនីកញ្ញា ពៅ បញ្ញាពេជ្រ ករណីឃាតកម្មលើមេដឹកនាំសហជីព លោក ហ៊ី វុទ្ធី និងការអារ កធ្វើគតព្រះសង្ឃខ្មែរកម្ពុជាក្រោម ព្រះនាម អ៊ាង សុខធឿន។ ករណីទាំងអម្បាលមាណខាងលើ មកដល់ពេលនេះ ពុំទាន់ត្រូវបានសមត្ថកិច្ចរើកមុខរកឃាតករ យកមកវិនិច្ឆ័យទោសនៅឡើយ ដែលប្រការនេះជាហេតុបង្កឱ្យ**មានបរិយាកាសភ័យខ្លាចដល់សកម្មជននយោបាយ និងអ្នកបោះឆ្នោត**។

២- <u>ទំនាស់គណបក្សនយោបាយៈ</u>

**ករណីប្តឹងផ្តល់ទៅលើសម្តេចក្រុមព្រះ** នៅតែបន្តពីសំណាក់មេដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិច។ **ករណីទំនាស់នេះមានចរិតជាលក្ខណៈនយោបាយ**។ មានការអនុម័តច្បាប់ឯកពន្ធភាពដ៏ចំរូងចំរាស់ និងលឿនបំផុត ដោយមានការជំរុញពីនាយករដ្ឋមន្ត្រី។ បន្ទាប់ពីមានច្បាប់នេះអ្នកអង្គម្ចាស់ ម៉ារី រណឫទ្ធិ បានដាក់ពាក្យបណ្តឹងទៅលើសម្តេចក្រុមព្រះ។ លើសពីនេះទៅទៀតមានការអន្តរាគមន៍ពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានជំរុញការដោះស្រាយបណ្តឹងនេះ តាមរយៈតុលាការហើយក៏បានព្រមានថា ឱ្យមាន**ការជាប់ទោសសិនទើបស្នើឱ្យសំរាលទោសជាក្រោយ** ទាក់ទិនទៅនឹងបណ្តឹងលើសម្តេចក្រុមព្រះ ពីបទរំលោភលើសេចក្តីទុកចិត្ត លក់ទីស្នាក់ការគណបក្សខុសច្បាប់។ ការអន្តរាគមន៍របស់នាយករដ្ឋមន្ត្រីនេះបានធ្វើចំពោះការលក់ដោះដូរទីស្នាក់ការគណបក្ស ហ៊្វុនស៊ិនប៉ិច ប៉ុន្តែមិនទាន់បានផ្តោតបន្ថែមទៀតលើបញ្ហាសំខាន់ ដូចជាការលក់ ឬ/និងការដូរដោះដូលទ្រព្យសម្បត្តិរដ្ឋជាច្រើនដោយខុសច្បាប់។ ការសង្កេតឃើញថា តុលាការបានចាត់ការបណ្តឹង

របស់ភាគីម្ខាងគឺបណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិច ចំណែកឯបណ្តឹងរបស់សម្តេចក្រុមព្រះ មិនត្រូវបានតុលាការជំរុញការដោះស្រាយឡើយ។ ជាលទ្ធផលសម្តេចក្រុមព្រះត្រូវបានកាត់ទោសឱ្យ ជាប់ពន្ធនាគាររយៈពេល **១៨** ខែចាប់ពីថ្ងៃចាប់ខ្លួនបាន និងបង់ប្រាក់ចំនួន **១៥** ម៉ឺនដុល្លារអាមេរិក ដែលជាហេតុធ្វើឱ្យព្រះ ប្រធានគណបក្សនេះ **មិនអាចយាងត្រឡប់**ដើម្បីចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។

**៣-** <u>**សកម្មភាពឃោសនាមុនកាលកំណត់**</u>

មានការបកស្រាយមិនទាន់ច្បាស់លាស់ អំពីការធ្វើយុទ្ធនាការឃោសនារកសំលេងឆ្នោតមុនកាលបរិច្ឆេទកំណត់ពីសំណាក់ គ.ជ.ប និងគ្មានច្បាប់ហាមឃាត់ផង។ គណបក្សមួយចំនួន ជាពិសេស **គណបក្សប្រជាជនកម្ពុជា** បាននិង**កំពុងធ្វើសកម្មភាពឃោសនា**នៅមូលដ្ឋានតាមរយៈការលើកបដា លើផ្លាក ការជួបប្រជុំ **ដោយពុំមានការរារាំង** ឬហាមឃាត់អ្វីឡើយ។ ចំណែកឯសកម្មភាពឃោសនារបស់**គណបក្សនយោបាយផ្សេងទៀត បែរជាត្រូវបានរារាំង**និងហាមឃាត់ពីសំណាក់អាជ្ញាធរមូលដ្ឋានដោយចោទគណបក្សនយោបាយផ្សេងៗនោះថា ធ្វើការឃោសនាខុសច្បាប់មុនកាលបរិច្ឆេទកំណត់។ ការប្រកួតប្រជែងរបៀបនេះ គឺមិនមានភាពយុត្តិធម៌ និងតម្លាភាពនោះទេ គឺមានន័យថា អ្នកប្រកួតប្រជែងម្ខាងត្រូវបានចាប់ជាប់ ហើយម្ខាងទៀតអាជ្ញាកណ្តាលបើកឱ្យធ្វើសកម្មភាពដោយសេរី។

ជាក់ស្តែង **ការអន្តរាគមន៍ របស់គណបក្សសមរង្ស៊ី** លើករណីទារប្រាក់ពីអាជីវករតាមផ្សារ ពីសំណាក់មន្ត្រីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ និងការអន្តរាគមន៍នៅតំបន់អភិវឌ្ឍន៍បឹងកក់ រាជធានីភ្នំពេញជាដើម **ត្រូវបានធ្វើការរារាំងដោយអាជ្ញាធរមូលដ្ឋាន**។ **អាជ្ញាធរទាំងនេះមិនដែលទៅរារាំងគណបក្សកាន់អំណាច** បើទោះបីគណបក្សកាន់អំណាច ធ្វើសកម្មភាពឃោសនានៅកន្លែងសាធារណៈក៏ដោយ។ ជាក់ស្តែង គឺការដាក់ពាក្យបណ្តឹងប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជាវិញ ពីសំណាក់គណបក្សសមរង្ស៊ីអំពីសកម្មភាពដើរបិទរ

តាមការអង្កេតរបស់ **ខុមហ្វ្រែល** នៅក្នុងខែកុម្ភៈនេះ **ទូរទស្សន៍ និងវិទ្យុរដ្ឋ និងទូរទស្សន៍ ស៊ីធីអិន គឺផ្សាយលំអៀងយ៉ាងខ្លាំងទៅរកគណបក្សប្រជាជនកម្ពុជា (រហូតដល់ ៧៩%)**។ ចំណែកឯ គណបក្សជំទាស់ សមរង្ស៊ី បានទទួល **៩%** ខណៈដែលគណបក្សហ៊្វុនស៊ិនប៉ិច ដែលជាគណបក្សដៃគូរក្នុងរាជរដ្ឋាភិបាលចំរុះ បានទទួលត្រឹមតែ **២%** ប៉ុណ្ណោះ និងគណបក្សនយោបាយ ចំនួន **៩** ផ្សេងទៀត បូកបញ្ចូលគ្នាបានទទួលត្រឹមតែ **១0%** ប៉ុណ្ណោះ។ មានតែគណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលត្រូវបានផ្សព្វផ្សាយបែបវិជ្ជមាន ៦៩% (ស្មើនឹង ៣៧ នាទី ៥៩ វិនាទី) នៃរយៈពេលសរុបផ្សាយពីគណបក្សនេះ ខណៈដែលគណបក្សនយោបាយផ្សេងៗទៀតដែលត្រូវបានផ្សព្វផ្សាយដ៏តិចតួចនោះ (រួមគ្នា បានត្រឹម ៣១%) ត្រូវគ្របដណ្តប់ដោយព័ត៌មាន បែបអព្យាក្រឹត និងអវិជ្ជមាន។

មានការប្រឹងប្រែងមួយរវាង គជប ក្រសួងព័ត៌មាន និង UNDP ដើម្បីបង្កើត**កម្មវិធីព័ត៌មានសមធម៌** ហើយផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិករបស់រដ្ឋ ដែលមានរយៈពេល ១៥ នាទីក្នុង ១ ថ្ងៃ ត្រូវបានគាំទ្រថវិកាដោយម្ចាស់ជំនួយតាមរយៈ UNDP ដែលមានទឹកប្រាក់ប្រមាណជាង ៦ សែនដុល្លាអាមេរិក។ ជាមួយគ្នានេះផងដែរ គជប និងក្រសួងព័ត៌មានបានសំរេចផលិត **កម្មវិធីផ្សព្វផ្សាយគោលនយោបាយរួមរបស់គណបក្សនយោបាយ** ក្នុងរយៈពេលយុទ្ធនាការឃោសនារយៈពេល ១៥ ថ្ងៃ។ ខុមហ្វ្រែល នឹងបន្តតាមឃ្លាំមើលកម្មវិធីផ្សាយខាងលើនេះ។

ទោះបីយ៉ាងណាក៏ដោយ រយៈពេល ១៥ ថ្ងៃ ដែលបានផ្តល់ឱ្យនេះ សំរាប់**គណបក្សនយោបាយផ្សេងៗទៀតគឺមិនអាចប្រៀបជាមួយនឹងគណបក្សប្រជាជនកម្ពុជា** ដែលបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាំងពីយូរមកហើយនោះបានទេ។

## ៥- <u>ការចែកអំណោយ និងប្រាក់កាក់ទៅអ្នកបោះឆ្នោត</u>

ការសង្កេតឃើញ មានសកម្មភាព**ចែកអំណោយយ៉ាងច្រើន ដោយសមាជិកគណបក្សនយោបាយមួយចំនួន ជាពិសេសគណបក្សប្រជាជនកម្ពុជា**។ ជាក់ស្តែងគណបក្សប្រជាជនកម្ពុជា ដោយបេក្ខជនមេឃុំមួយចំនួន របស់គណបក្សនេះ បាន និងកំពុងធ្វើយុទ្ធនាការចែកអំណោយដល់ប្រជាពលរដ្ឋនូវសារុង អាវ និងថវិកា (រាប់ពាន់រៀលក្នុងម្នាក់) នៅកន្លែងជាច្រើន។ **ប្រសិនបើសកម្មភាពនេះ បន្តមាននៅក្នុងអំឡុងពេលឃោសនាបោះឆ្នោត នោះគឺជាការរំលោភធ្ងន់ធ្ងរទៅលើនីតិវិធីរបស់ គជប ដែលមានន័យថាជា "ការទិញសន្លឹកឆ្នោត"**។ សកម្មភាពចែកអំណោយមួយចំនួនក៏ត្រូវបានផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ និងទូរទស្សន៍) ថែមទៀតផងដែរ។

## ៦- <u>ការព្រួយបារម្ភក្នុងការបាត់បង់សិទ្ធិបោះឆ្នោត</u>

ការសង្កេតរកឃើញថា **បញ្ជីឈ្មោះបោះឆ្នោតផ្លូវការមិនទាន់មានគុណភាព** បានបង្កជាការ**ព្រួយបារម្ភយ៉ាងខ្លាំងពីសំណាក់គណបក្សនយោបាយមួយចំនួន និងអ្នកបោះឆ្នោតជាច្រើន** ដែលបានរអ៊ូរទាំអំពីបញ្ហាខុសទិន្នន័យនានារវាងបញ្ជីឈ្មោះ និងឯកសារបញ្ជាក់អត្តសញ្ញាណ ដែលអាចបណ្តាលឱ្យអ្នកបោះឆ្នោតទាំងនោះ **បាត់បង់សិទ្ធិបោះឆ្នោត**។ អ្នកបោះ-ឆ្នោតមួយចំនួនបានបញ្ជាក់ប្រាប់ថា ខ្លួនបានកែទិន្នន័យរួចម្តងមកហើយ នៅក្នុងកំឡុងពេលធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត តែនៅខុសដដែល។ ចំណែកឈ្មោះអ្នកខ្លះទៀត មិនបានសុំកែ បែរជាត្រូវបានគេកែឱ្យខុសទៅវិញ។ **ប័ណ្ណបោះ-ឆ្នោតដែលលែងត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់នៅថ្ងៃបោះឆ្នោត** គឺជាការព្រួយបារម្ភមួយដែលប្រជាពលរដ្ឋពុំទាន់យល់អំពី

បញ្ហានេះ ម៉្យាងទៀតពុំទាន់មានឯកសារសំគាល់អត្តសញ្ញាណ **អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងការបំពេញទម្រង់១០១៨ ដែលគ្មានរូបថត** ម៉្យាងវិញទៀត **ប្រជាពលរដ្ឋបានរអ៊ូរទាំអំពីភាពស្មុគស្មាញក្នុងការបំពេញទំរង់នេះ**។ ជាការគួរឱ្យកត់សម្គាល់ ឆ្លើយតបនឹងកង្វល់នេះ គជប បានចេញជាសេចក្តីណែនាំមួយបញ្ជាក់អំពីកំរិតកំហុសទិន្នន័យរវាងបញ្ជីឈ្មោះ និងឯកសារបញ្ជាក់អត្តសញ្ញាណ ដែលអាចប្រើប្រាស់នៅថ្ងៃបោះឆ្នោតបាន។ ប៉ុន្តែការព្រួយបារម្ភនៅត្រង់ថា តើការអនុវត្តន៏ជាក់ស្តែង នឹងនៅមានជួប**បញ្ហាអ្វីខ្លះទៀត?**

**ដំណើរការចែកប័ណ្ណព័តិមានអ្នកបោះឆ្នោតលើកទី២នេះ នៅតែជាការព្រួយបារម្ភដដែល** ដោយសារតែចំនួនប័ណ្ណដែលបានចែកនៅតែមិនទាន់បានដល់ដៃអ្នកបោះឆ្នោតប្រហែលចំនួន១លាន៤សែននាក់មានន័យថា នៅមានអ្នកបោះឆ្នោតជាច្រើនមិនទាន់បានទទួលព័តិមានពាក់ព័ន្ធនឹងការបោះឆ្នោតរបស់ខ្លួននៅឡើយ។ ការសង្កេតឃើញ**នៅតែមានភាពមិនប្រក្រតីអំពីការរើសអើងគណបក្សនយោបាយ** ប្រសិទ្ធភាពនៃការចែកមានការយឺត ការមិនគោរពតាមសេចក្តីណែនាំ នៅតែបន្តកើតមានឡើង។

**៧- ភាពមិនតម្លាភាពក្នុងដំណើរការបោះពុម្ពសន្លឹកឆ្នោត**

សង្គមស៊ីវិល និងគណបក្សនយោបាយមួយចំនួន បានសំដែងនូវការ**ព្រួយបារម្ភ និងមានមន្ទិល**ជាខ្លាំងចំពោះដំណើរការបោះពុម្ពសន្លឹកឆ្នោតនៅក្រុមហ៊ុន **លី ទ៊ាន់ហុខ** ដែល គជប **មិនបានបើកចំហឱ្យ**មានការអង្កេតតាមដានជាប្រចាំពីសំណាក់អ្នកសង្កេតការណ៍។ ដំណើរការបោះពុម្ពសន្លឹកឆ្នោត ដែលពុំ**មានតម្លាភាព**អាចធ្វើឱ្យប៉ះពាល់ដល់**ការទុកចិត្តលើគុណភាព**សុវត្ថិភាព និងបរិមាណសន្លឹកឆ្នោតពីសំណាក់ភាគីដែលពាក់ព័ន្ធនឹងការបោះឆ្នោត។

**ខុមហ្វ្រែល** មានការ**សោកស្តាយចំពោះការឆ្លើយតបជាអវិជ្ជមាន**ពីគជប ដែលបានបដិសេធសិទ្ធិចូលសង្កេតការណ៍ដោយពុំបានបញ្ជាក់អំពីមូលហេតុ ដែលមិនអាចឱ្យ ខុមហ្វ្រែល ធ្វើការវាយតម្លៃទៅលើដំណើរការបោះពុម្ពសន្លឹកឆ្នោតនេះបានទេ ព្រមទាំងមិនអាចឆ្លើយតបទៅនឹងមតិជាតិ និងភាគីដែលជាប់ពាក់ព័ន្ធនឹងការបោះឆ្នោតដែលបានចោទជាសំណួរថា **តើដំណើរការបោះពុម្ពសន្លឹកឆ្នោត នៅកម្ពុជានេះប្រព្រឹត្តទៅ ដោយមានតម្លាភាព និងធានាបានថា សន្លឹកឆ្នោតដែលលើសឬខ្វះចំនួននោះថាជា កំហុសបច្ចេកទេស ឬជាចេតនានយោបាយ ឬយ៉ាងណានោះទេ។**

**៨- ការចូលរួមរបស់ស្ត្រីជាបេក្ខនារី**

យោងតាមលទ្ធផលចុះបញ្ជីបេក្ខជនគណបក្សនយោបាយរបស់ គ ជ ប ចំនួនបេក្ខនារីឈរបោះឆ្នោតជ្រើសរើសឃុំ/សង្កាត់អាណត្តិទី ២ នេះ **មានការកើនឡើង**ពី ១៦% ក្នុងឆ្នាំ ២០០២ (សរុបក្នុងចំណោម ៨ គណបក្ស នយោបាយ) ទៅ ២១% ក្នុងឆ្នាំ ២០០៧ (សរុបក្នុងចំណោម ១២ គណបក្សនយោបាយ)។ ចំនួនបេក្ខនារីលំដាប់លេខមួយ លេខពីរ និងលេខបីនៃគណបក្សទាំង១២ មានចំនួន២៣២៨។ លើសពីនេះទៅទៀត **បេក្ខនារីដែលចិតនៅបញ្ជីលើក៏មានការកើនឡើង** គួរឱ្យកត់សំគាល់ដែរ។ ឧទាហរណ៍គណបក្សប្រជាជនកម្ពុជា បានតម្លើងចំនួនបេក្ខនារី លំដាប់ទីមួយ ពី ៣២ ក្នុងឆ្នាំ ២០០២ មក ៦៦ ក្នុងឆ្នាំ ២០០៧នេះ បេក្ខនារីលំដាប់ទីមួយគណបក្ស ហ៊្វុនស៊ិនប៉ិចកើនពី ៩៥ ក្នុងឆ្នាំ ២០០២ មក ៨៣ ក្នុងឆ្នាំ ២០០៧ និងបេក្ខនារីលំដាប់ទីមួយគណបក្សសមរង្ស៊ី កើនពី ៧៨ ក្នុងឆ្នាំ ២០០២ មក ៩៦ ក្នុងឆ្នាំ ២០០៧។

ចំណែកឯគណបក្សនរោត្តមរណឫទ្ធិ ដែលទើបបង្កើតថ្មីនេះ ក៏បានខិតខំដាក់បញ្ជីបេក្ខនារីលំដាប់លើ ប្រហាក់ប្រហែលនឹងគណបក្សទាំងបីខាងលើដែរ ដែលមានបេក្ខនារីលំដាប់ទីមួយចំនួន ៧៩ នាក់)។ ការសង្កេតរកឃើញថា ខេត្ត/ក្រុង ដែលមានបេក្ខនារីឈរឈ្មោះលំដាប់លើ (គិតពីលេខ ១ ដល់លេខ ៣) ច្រើនជាងគេ នោះគឺមាន ខេត្តកំពង់ចាម ២៤៧ នាក់ បន្ទាប់មកខេត្តកណ្តាល ២៤០ នាក់ ក្រុងភ្នំពេញ ២០៤ នាក់ បាត់ដំបង ១៨៣ នាក់ កំពត ១៤៧ នាក់ ព្រៃវែង ១២២ នាក់។ **ការព្រួយបារម្ភនៅត្រង់ថា តើក្រោយពេលជាប់ឆ្នោត គណបក្សនយោបាយប្តេជ្ញាថា នឹងមិនដកស្ត្រីជាប់ឆ្នោត ចេញពីសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ដែរឬយ៉ាងណា។** ជាប្រការគួរឱ្យកត់សំគាល់ថា គណបក្សស្ត្រីដែលធ្លាប់បានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទីមួយនោះ មិនបានចូលក្នុងការបោះឆ្នោតលើកនេះទេវិញ ម្យ៉ាងមេដឹកនាំគណបក្សទាំង ១២ ដែលចូលរួមការបោះឆ្នោតលើកនេះសុទ្ធតែជាបុរស។

**សូមអរគុណ!**

*បេសកកម្ម របស់ **ខុមហ្វ្រែល** គឺ "ជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះសាធារណជន យល់យ៉ាងច្បាស់អំពីដំណើរការលទ្ធិប្រជាធិបតេយ្យ មិនត្រឹមតែមុនពេលបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រោយ និងចន្លោះពេលបោះឆ្នោតទៀតផង។ ដើម្បីសំរេចបេសកកម្មនេះ **ខុមហ្វ្រែល** រៀបចំការអប់រំ និងវេទិកាសាធារណៈ ក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសម្រេចនានា។ លើកទឹកចិត្តការចូលរួមការតស៊ូមតិ បញ្ចុះបញ្ចូល ដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោត ដែលបង្កើនទូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត។ និងចុងក្រោយ ដោយផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័សដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលម្អៀង និងមិនប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តការងាររបស់មន្ត្រីជាប់ឆ្នោត។"*

***សំរាប់ព័ត៌មានលំអិតសូមទាក់ទង:***


- លោក **ធន សារាយ** តំណាងទី១ ខុមហ្វ្រែល ០១៦ ៨៨ ០៥ ០៩
- លោក **យង់ គិមអេង** សមាជិកគណៈកម្មាធិការនាយក ខុមហ្វ្រែល ០១៦ ៨២ ៨២ ១១
- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧